# ព័ត៌មានអំពីដំណើរកម្សាន្តសម្រាប់ឪពុកម្ដាយ/អ្នកថែទាំ
# Excursion information for parents/carers

សូមគោរពមាតាបិតា/អ្នកថែទាំ

ដំណើរកម្សាន្តមួយកំពុងត្រូវបានគ្រោងទុកសម្រាប់ថ្នាក់របស់កូនអ្នក ដើម្បីបំពេញកិច្ចការដែលកំពុងធ្វើនៅថ្នាក់រៀន។ ព័ត៌មានលម្អិតនៃដំណើរកម្សាន្តមានចុះខាងក្រោម។

## Excursion details for completion by organising teacher
## ព័ត៌មានលម្អិតអំពីដំណើរកម្សាន្ត

| | | | |
|---|---|---|---|
| Place of excursion<br>កន្លែងដំណើរកម្សាន្ត | | Date/s of excursion<br>កាលបរិច្ឆេទដំណើរកម្សាន្ត | |
| Place of departure<br>កន្លែងចេញដំណើរ | | Time of departure<br>ម៉ោងចេញដំណើរ | |
| Place of return<br>កន្លែងត្រឡប់មកវិញ | | Time of return<br>ម៉ោងត្រឡប់មកវិញ | |
| Cost of excursion<br>តម្លៃដំណើរកម្សាន្ត | | Payment due date<br>កាលបរិច្ឆេទទូទាត់ប្រាក់ | |

Excursion objectives
គោលបំណងនៃដំណើរកម្សាន្ត

Transport details
ព័ត៌មានលម្អិតអំពីការដឹកជញ្ជូន

Staff member with emergency care training
សមាជិកបុគ្គលិកដែលមានការបណ្ដុះបណ្ដាលផ្នែកថែទាំសង្គ្រោះបន្ទាន់

Staff member with Cardio Pulmonary Resuscitation (CPR) training
សមាជិកបុគ្គលិកដែលមានការបណ្ដុះបណ្ដាលផ្នែកសង្គ្រោះដង្ហើម និងបេះដូងឱ្យដំណើរការឡើងវិញ (CPR)

Other supervisory staff
បុគ្គលិកត្រួតពិនិត្យឯទៀត

Teacher to tick what students need to bring
សិស្សនឹងត្រូវយកវត្ថុខាងក្រោមមកជាមួយ សម្រាប់ដំណើរកម្សាន្តនេះ

- ☐ សម្លៀកបំពាក់ហែលទឹក កន្សែងងូតទឹក និងថង់ប្លាស្ទិក
  Swimsuit, towel and plastic bag
- ☐ សម្លៀកបំពាក់ការពារកុំឱ្យជ្រាបទឹក ឧទាហរណ៍ អាវភ្លៀង
  Waterproof clothing e.g. raincoat
- ☐ សម្លៀកបំពាក់សម្រាប់ផ្លាស់ប្ដូរ
  Change of clothing
- ☐ សម្លៀកបំពាក់កក់ក្ដៅ
  Warm clothing
- ☐ មួកការពារកម្ដៅថ្ងៃ និងឡេការពារកម្ដៅថ្ងៃ
  Sunhat and sunscreen
- ☐ យកអាហារសម្រន់ អាហារថ្ងៃត្រង់ និងភេសជ្ជៈពីផ្ទះ
  Bring snacks, lunch and drink from home
- ☐ អាចទិញអាហារថ្ងៃត្រង់បានក្នុងអំឡុងពេលដំណើរកម្សាន្ត
  Lunch can be bought during the excursion
- ☐ តម្លៃអាហារថ្ងៃត្រង់ត្រូវបានដាក់បញ្ចូលក្នុងដំណើរកម្សាន្ត
  Cost of lunch is included in excursion cost
- ☐ ឯកសណ្ឋានសាលាពេញ
  Full school uniform
- ☐ ផ្សេងទៀត
  Other

សកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងដំណើរកម្សាន្តនេះ ត្រូវបានគូសសញ្ញាធីកនៅខាងក្រោម ហើយព័ត៌មានបន្ថែមត្រូវបានផ្តល់ជូននៅលើទំព័រខាងក្រោម ប្រសិនបើពាក់ព័ន្ធ

Teacher to tick any other activities involved in this excursion

- ☐ មិនមានសកម្មភាពផ្សេងទៀតទេ<br>No other activities
- ☐ ការធ្វើដំណើរតាមយន្តហោះ<br>Travel by air
- ☐ ការធានារ៉ាប់រងលើការធ្វើដំណើរ<br>Travel insurance
- ☐ សកម្មភាពហែលទឹក<br>Swimming activity
- ☐ សកម្មភាពជាមួយទឹក<br>Water activitiy
- ☐ ដំណើរកម្សាន្តមួយយប់<br>Overnight excursion

## សេចក្តីណែនាំអំពីដំណើរកម្សាន្តមួយយប់ (Overnight excursion advice)

ព័ត៌មានបន្ថែមខាងក្រោមត្រូវបានផ្តល់ជូន សម្រាប់ដំណើរកម្សាន្តដែលពាក់ព័ន្ធនឹងការស្នាក់នៅមួយយប់។

Teacher to complete if relevant. Consider adding advice on the number of students and teachers who will be attending and if protective or special equipment will be required.

កន្លែងស្នាក់នៅដែលបានកក់ទុក (Where accommodation is booked)

| |
|---|
| |

ព័ត៌មានបន្ថែម (Additional information)

| |
|---|
| |

## សេចក្តីណែនាំអំពីការធានារ៉ាប់រងលើការធ្វើដំណើរ (Travel insurance advice)

ក្រសួងសូមណែនាំថាមាតាបិតា/អ្នកថែទាំ គួររៀបចំការធានារ៉ាប់រងលើការធ្វើដំណើរសម្រាប់សិស្ស សម្រាប់ដំណើរកម្សាន្តដែលពាក់ព័ន្ធនឹងការធ្វើដំណើរតាមយន្តហោះ។

## សេចក្តីណែនាំអំពីសកម្មភាពហែលទឹក (Swimming activity advice)

សម្រាប់ដំណើរកម្សាន្តដែលពាក់ព័ន្ធនឹងសកម្មភាពហែលទឹក មាតាបិតា/អ្នកថែទាំត្រូវតែបំពេញ 'បែបបទសេចក្តីណែនាំអំពីសកម្មភាពហែលទឹក' ជាភាសាអង់គ្លេស ដែលជូនដំណឹងអំពីសមត្ថភាពហែលទឹករបស់កូនពួកគេ ហើយប្រគល់វាទៅសាលារៀនវិញ។ បែបបទនេះ ផ្តល់ព័ត៌មានអំពីប្រភេទនៃសកម្មភាពហែលទឹកនានាដែលនឹងកើតឡើង កន្លែងដែលសកម្មភាពទាំងនេះនឹងត្រូវបានធ្វើឡើង និងការយល់ព្រមដើម្បីចូលរួមក្នុងសកម្មភាពទាំងនេះ។ សាលារៀននឹងផ្តល់ឧបករណ៍បណ្តែតខាងក្រោម ដល់សិស្សដែលត្រូវការជំនួយក្នុងទឹក។

ឧបករណ៍បណ្តែតដែលត្រូវផ្តល់ជូន ប្រសិនបើពាក់ព័ន្ធ

Types of flotation devices to be provided by the school and how they will be used

| |
|---|
| |

## សេចក្ដីណែនាំអំពីសកម្មភាពជាមួយទឹក (Water activity advice)

សម្រាប់ដំណើរកម្សាន្តដែលពាក់ព័ន្ធនឹងសកម្មភាពជាមួយទឹក មាតាបិតា/អ្នកថែទាំត្រូវតែបំពេញ 'បែបបទសេចក្ដីណែនាំអំពីសកម្មភាពជាមួយទឹក' ជាភាសាអង់គ្លេស ដែលណែនាំអំពីសមត្ថភាពហែលទឹករបស់កូនពួកគេ ហើយប្រគល់វាទៅសាលារៀនវិញ។ នេះគឺជាជាវិធានការប្រុងប្រយ័ត្ន។ ទោះបីជាគ្មានសកម្មភាពហែលទឹកត្រូវបានបម្រុងទុកក្ដី សិស្សអាចធ្លាក់ទៅក្នុងទឹកដោយចៃដន្យ។ បែបបទនេះ ផ្ដល់ព័ត៌មានអំពីប្រភេទនៃសកម្មភាពជាមួយទឹកនានាដែលនឹងកើតឡើង កន្លែងដែលសកម្មភាពទាំងនេះនឹងត្រូវបានធ្វើឡើង និងការយល់ព្រមដើម្បីចូលរួមក្នុងសកម្មភាពទាំងនេះ។

## ការណែនាំអំពីឯកជនភាព (Privacy advice)

ព័ត៌មានដែលបានស្នើសុំនៅលើបែបបទនេះ កំពុងត្រូវបានប្រមូលដោយក្រសួងអប់រំរដ្ឋ NSW។ ព័ត៌មាននេះកំពុងទទួលបាន ក្នុងគោលបំណងដើម្បីបញ្ជាក់ព័ត៌មានវេជ្ជសាស្ត្រដែលពាក់ព័ន្ធ លក្ខខណ្ឌតម្រូវនានា និងតម្រូវការទាក់ទងនឹងការថែទាំសុខភាពផ្សេងទៀតអំពីកូនរបស់អ្នកដែលកំពុងចុះឈ្មោះចូលរៀននៅសាលា ហើយនរណាដែលអាចចូលរួមក្នុងដំណើរកម្សាន្តនៅសាលារៀន សកម្មភាពកីឡា ឬសកម្មភាពអប់រំ ឬសកម្មភាពសាលាផ្សេងទៀតដែលធ្វើឡើងដោយ ឬរួមជាមួយនឹងសាលារៀននេះ។

ព័ត៌មាននឹងត្រូវបានប្រើប្រាស់ដោយសាលារៀនដើម្បីធ្វើផែនការ គាំទ្រសិស្ស និងកាត់បន្ថយហានិភ័យនៅពេលធ្វើដំណើរកម្សាន្តរបស់សាលា ឬសកម្មភាពសាលាដែលពាក់ព័ន្ធផ្សេងទៀត។

បុគ្គល ឬទីភ្នាក់ងារផ្សេងទៀតដែលអាចត្រូវបានផ្ដល់ព័ត៌មាននេះ រួមមាន ប៉ុន្តែអាចមានលើសពីនេះ អ្នកស្ម័គ្រចិត្ត និងសមាជិកនៃអង្គការខាងក្រៅដែលចូលរួមជាមួយសាលារៀន ឬក្រៅពីនេះពាក់ព័ន្ធនឹងការធ្វើផែនការ ឬការផ្ដល់ជូនដំណើរកម្សាន្ត កីឡា ឬសកម្មភាពសាលាផ្សេងទៀត ហើយនិងបុគ្គលដែលអាចត្រូវបានហៅឱ្យផ្ដល់ការព្យាបាលថែទាំសុខភាព ឬជំនួយផ្សេងទៀតក្នុងអំឡុងពេល ឬជាផលវិបាកនៃដំណើរកម្សាន្ត ឬសកម្មភាពបែបនេះ។

ការផ្ដល់ព័ត៌មាននេះគឺស្ម័គ្រចិត្ត ទោះជាយ៉ាងណាក្ដី ប្រសិនបើអ្នកមិនផ្ដល់ព័ត៌មានទាំងអស់ ឬព័ត៌មានណាមួយដែលបានស្នើសុំទេ កូនរបស់អ្នកមិនអាចចូលរួមក្នុងដំណើរកម្សាន្តបានទេ។ ក្នុងកាលៈទេសៈបែបនេះ សាលារៀននឹងរៀបចំឱ្យមានបទពិសោធន៍អប់រំដ៏ត្រឹមត្រូវមួយផ្សេងទៀត។

ការផ្ដល់ព័ត៌មាននេះនឹងជួយយ៉ាងសំខាន់ដល់សាលារៀន ក្នុងការរៀបចំផែនការសកម្មភាពអប់រំដែលមានសុវត្ថិភាពកាន់តែប្រសើរ។ ព័ត៌មាននេះនឹងត្រូវបានរក្សាទុកដោយសុវត្ថិភាព។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការផ្ដល់ព័ត៌មាននេះ សូមទាក់ទងមកនាយកសាលាដើម្បីពិភាក្សាបន្ថែម។

អ្នកអាចកែតម្រូវព័ត៌មានផ្ទាល់ខ្លួនណាមួយដែលបានផ្ដល់ឱ្យនៅពេលណាក៏បាន ដោយទាក់ទងមកការិយាល័យសាលា តាមលេខទូរសព្ទខាងក្រោម។

Teacher to complete the following information

School name ______________________________
ឈ្មោះសាលារៀន

School phone number ______________________________
លេខទូរសព្ទរបស់សាលារៀន

Name and signature of excursion coordinator ______________________________
ឈ្មោះ និងហត្ថលេខារបស់អ្នកសម្របសម្រួលដំណើរកម្សាន្ត

Name and signature of principal ______________________________
ឈ្មោះ និងហត្ថលេខារបស់នាយកសាលា

Date ______________________________
កាលបរិច្ឆេទ

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅសាលារៀន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់  ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។